CAMBODIA RICE FEDERATION

# សហព័ន្ធស្រូវអង្ករកម្ពុជា

## សមាជិកភាព



ធ្វើបច្ចុប្បន្នភាព៖ ឆ្នាំ២០២១



# មាតិកា

១. អំពីសហព័ន្ធស្រូវអង្ករកម្ពុជា

២. អត្ថប្រយោជន៍របស់សមាជិក

៣. នីតិវិធីស្នើសុំចូលជាសមាជិក

៤. កាតព្វកិច្ចរបស់សមាជិក



# ១. អំពីសហព័ន្ធស្រូវអង្ករកម្ពុជា

សហព័ន្ធស្រូវអង្ករកម្ពុជា (ស.អ.ក) ជាស្ថាប័នឯកជនតែមួយគត់ តំណាងឱ្យវិស័យស្រូវឧស្សាហកម្ម ស្រូវអង្ករនៅកម្ពុជា ដែលប្រមូលផ្តុំអ្នកពាក់ព័ន្ធទាំងអស់ មកពីអ្នកផលិត អ្នកកិនកែច្នៃ អ្នកនាំចេញ និងអ្នកផ្តល់សេវាពាក់ព័ន្ធ។ ស្ថាប័នមួយនេះត្រូវបានបង្កើតឡើងតាមរយៈ ការបោះឆ្នោត ដោយសមាជិកស្ថាបនិក ២១៣រូប នាថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ និងត្រូវបានទទួលស្គាល់ជាផ្លូវការដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ២២៨ អនប្រ.បក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤ និងអនុក្រឹត្យលេខ១៧២ អនប្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩។

សហព័ន្ធស្រូវអង្ករកម្ពុជា ជាស្ថាប័នឯកជនតែមួយគត់ សម្រាប់វិស័យស្រូវអង្ករនៅកម្ពុជា ដែលស្ថិតក្រោមអភិបាលកិច្ចផ្នែកបច្ចេកទេសរបស់ក្រសួងពាណិជ្ជកម្ម និងជាដៃគូរបស់រាជរដ្ឋាភិបាល ចូលរួមរាល់សកម្មភាពរបស់សហគមន៍ស្រូវអង្ករនៃបណ្តាប្រទេសអាស៊ាន ចូលរួមចរចារជាមួយរដ្ឋាភិបាលនៃបណ្តាប្រទេសនាំចូល រៀបចំសន្និសីទតាំងពិព័រណ៍ស្រូវ-អង្ករថ្នាក់ជាតិ និងអន្តរជាតិជាប្រចាំឆ្នាំ ព្រមទាំងចូលរួមក្នុងការងារផលិតពូជស្រូវសម្រាប់ចែកចាយជូនប្រជាកសិករ។

នាថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ សហព័ន្ធស្រូវអង្ករកម្ពុជា បានរៀបចំមហាសន្និបាតប្រចាំឆ្នាំ និងការបោះឆ្នោតក្រុមប្រឹក្សាភិបាលអាណត្តិទី៣ ដោយជ្រើសរើសបានសមាជិកក្រុមប្រឹក្សាភិបាលចំនួន ២៥រូប ដែលជាតំណាង មកពីអ្នកនាំចេញអង្ករ រោងម៉ាស៊ីនកិនស្រូវ និងសហគមន៍កសិករ។

## ទស្សនវិស័យ

ការអភិវឌ្ឍវិស័យស្រូវ-អង្ករ ប្រកប ដោយតម្លាភាព និងសីលធម៌

## បេសកកម្ម

សហព័ន្ធស្រូវអង្ករកម្ពុជាបានប្តេជ្ញាចិត្ត យ៉ាងមុតមាំក្នុងការ លើកកម្ពស់ផលិតភាព ដើម្បីធ្វើឲ្យប្រសើរឡើងនូវ បច្ចេកទេស កសិកម្ម និងការកិនកែច្នៃអង្ករកម្ពុជា ការកាត់ បន្ថយចំណាយថ្លៃដើមក្នុងដំណើរការនាំចេញ ការលើក កម្ពស់ក្រមប្រតិបត្តិមួយ ក្នុងក្របខណ្ឌនៃវិស័យស្រូវអង្ករ ទាំងមូល ដែលមានតម្លៃសម្រាប់ការវិនិយោគ និងការអនុវត្ត នូវស្តង់ដារក្រមសីលធម៌ខ្ពស់បំផុត ក្នុងប្រតិបត្តិការរបស់ យើងទាំងអស់គ្នា ជាមួយនឹងភាគីពាក់ព័ន្ធ ដើម្បីការពារ គុណភាពអង្កររយៈពេលវែង កេរ្តិ៍ឈ្មោះ និងនិរន្តរភាពនៃការ ផ្គត់ផ្គង់អង្ករកម្ពុជា។

## គោលដៅ

១. ជំរុញការនាំចេញឱ្យបាន
**១លានតោន** ចាប់ពីឆ្នាំ២០២២
២. បង្កភាពងាយស្រួលដល់អ្នក
ប្រកបរបរក្នុងវិស័យស្រូវ-អង្ករកម្ពុជា
ដើម្បី **បង្កើនប្រាក់ចំណេញ**

## គុណតម្លៃ



# រចនាសម្ព័ន្ធគ្រប់គ្រង




គណៈកម្មាធិការប្រតិបត្តិ
វិនិយោគ និង ហិរញ្ញវត្ថុ
ទីផ្សារ និង ការនាំចេញ
គំនិតច្នៃប្រឌិត និង បច្ចេកវិទ្យា
ការកាត់បន្ថយថ្លៃដើម សហគមន៍ និង រោងម៉ាស៊ីនកិនស្រូវ
ក្រមសីលធម៌ និង វិន័យ
ជំរុញផលិតកម្ម ស្រូវពូជ
សហករណ៍


ស.អ.ក
សហព័ន្ធស្រូវអង្ករកម្ពុជា
CAMBODIA RICE FEDERATION
សមាសភាពក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា អាណត្តិទី៣
3rd Mandate Board of Directors of Cambodia Rice Federation
ប្រធានក្រុមប្រឹក្សាភិបាល
Chairman
ប្រធានសហព័ន្ធ
President
អនុប្រធានក្រុមប្រឹក្សាភិបាល
Vice-Chairmen
អនុប្រធានសហព័ន្ធ
Vice-Presidents
លោក ស៊ឺ រ៉ានី
Mr. SEU Rany
ឧកញ៉ា វង្ស ប៊ុនហេង
Oknha. VONG Bunheng
ឧកញ៉ា ហ៊ុន ឡាក់
Oknha. HUN Lak
ឧកញ៉ា សុង សារ៉ន
Oknha. SONG Saran
ឧកញ៉ា ចាន់ សុឃាំង
Oknha. CHAN Sokheang
ឧកញ៉ា ច្រាយ សុន
Oknha. CHRAY Son
លោក ភូ វាសនា
Mr. PHOU Veasna
អ្នកស្រី គីម ស្រីរ័ត្ន
Mrs. KIM Sreyroth
លោក ឡាយ ឈុនហួ
Mr. LAY ChhunHour
សមាជិកក្រុមប្រឹក្សាភិបាល
Members of Board of Directors
កញ្ញា សៅ ខេណ្ណារ័ត្ន
Ms. SAO Khenaroth
លោក រស់ សុផារិទ្ធ
Mr. ROS Sopharith
ឯកឧត្តម វិញ ជាង
H.E. VINH Cheang
លោក ហេង ផេង
Mr. HENG Pheng
លោក ឈិត ប៊ុនថន
Mr. CHHITH Bounthan
លោក ឈុន ធំ
Mr. CHHUN Thom
លោក យ៉ន សុវណ្ណ
Mr. YON Sovann
លោក ហ៊ាង គីមសួរ
Mr. HEANG Kimsua
លោក យិន វេងអាន
Mr. YIN Veng An
លោក ម៉េង បូរ៉ាន់
Mr. MENG Boran
លោក ហួរ លុច
Mr. HOUR Luch
លោក ហ៊ី ហ៊ត
Mr. HI Hort
លោក យន់ ហុង
Mr. YUN Hong
លោក តែ សឿផាន់
Mr. TE Surphann
លោក ចាន់ សុធា
Mr. CHAN Sothea
លោក និល សុភាព
Mr. NIL Sopheap

# ២. អត្ថប្រយោជន៍របស់សមាជិក

១

### បញ្ចុះតម្លៃនៅកំពង់ផែ

ទទួលបានការបញ្ចុះតម្លៃការប្រើប្រាស់សេវាមួយចំនួននៅក្នុងកំពង់ផែក្រុងព្រះសីហនុ និងកំពង់ផែភ្នំពេញ

២

### វិញ្ញាបនបត្របញ្ជាក់ប្រភពដើម

ទទួលបានការសម្របសម្រួលជាមួយក្រសួងពាណិជ្ជកម្មលើវិញ្ញាបនបត្រប្រភពដើម

៣

### ប្រតិវេទគយនាំចេញ

ទទួលបានការសម្របសម្រួលជាមួយអគ្គនាយកដ្ឋានគយ លើបញ្ហាបំពេញបែបបទនាំចេញ

៤

### លិខិតបញ្ជាក់អនាម័យ និងភូតគាមអនាម័យ

ទទួលបានការសម្របសម្រួលជាមួយអគ្គនាយកដ្ឋានកសិកម្មលើលិខិតបញ្ជាក់អនាម័យ និងភូតគាមអនាម័យ

## ៥

### ទទួលឥណទានពីធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងធនាគារពាណិជ្ជ

ទទួលបានព័ត៌មាននិងការសម្របសម្រួលលើការ ទទួលឥណទានពីធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម និងធនាគារពាណិជ្ជមួយចំនួន

## ៦

### ព័ត៌មានពីច្បាប់ បទប្បញ្ញត្តិ លក្ខខណ្ឌ ចាំបាច់នានាក្នុងវិស័យស្រូវអង្ករ

ទទួលបានព័ត៌មានស្ដីអំពីបច្ចុប្បន្នភាពនៃច្បាប់ និងបទប្បញ្ញត្តិនានារបស់កម្ពុជា លក្ខខណ្ឌចាំបាច់ នានារបស់ប្រទេសនាំចូល ព័ត៌មាននានាដែល ពាក់ព័ន្ធជាមួយវិស័យស្រូវអង្ករ

## ៧

### ចូលរួមវេទិកាធុរកិច្ច ការតាំងពិព័រណ៍ ទស្សនកិច្ចក្នុង និងក្រៅប្រទេស

ទទួលបានព័ត៌មាននិងចូលរួមក្នុងវេទិកា ធុរកិច្ចនានា ការតាំងពិព័រណ៍ ទស្សនកិច្ច ក្នុងនិងក្រៅប្រទេស ក្រោមការសម្រប សម្រួលរបស់សហព័ន្ធស្រូវអង្ករកម្ពុជា

## ៨

### កិច្ចប្រជុំវេទិការាជរដ្ឋាភិបាល ផ្នែកឯកជន

ទទួលបានព័ត៌មាននិងចូលរួមនៅក្នុង កិច្ចប្រជុំនានារបស់ក្របខ័ណ្ឌក្រុម ការងារទាំង១៣ និងអនុគណៈកម្មការ ទាំង៣ របស់ផ្នែកឯកជន នៃវេទិការាជ រដ្ឋាភិបាល និងវិស័យឯកជន

## ៩

### ចូលរួមបោះឆ្នោត និងមានសិទ្ធិឈរឈ្មោះ

ចូលរួមបោះឆ្នោត និងមានសិទ្ធិឈរឈ្មោះជាតំណាងអោយវិស័យស្រូវអង្ករ ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា

## ១០

### បង្កើតទំនាក់ទំនងក្នុងការពង្រីក និងពង្រឹងអាជីវកម្មរបស់ខ្លួន

ចូលរួមសកម្មភាពនិងកម្មវិធីនានាក្នុងប្រទេស និងក្រៅប្រទេស ដែលសម្របសម្រួលដោយសហព័ន្ធស្រូវអង្ករកម្ពុជា ដើម្បីបង្កើតទំនាក់ទំនង ក្នុងការពង្រីក និងពង្រឹងអាជីវកម្មរបស់ខ្លួន និងការងារសង្គមនានា

## ១១

### ចូលរួមកម្មវិធីបណ្តុះបណ្តាល

ទទួលបានព័ត៌មាន និងការចូលរួមកម្មវិធីបណ្តុះបណ្តាលដែលរៀបចំដោយសហព័ន្ធស្រូវអង្ករកម្ពុជា និងនៅខាងក្រៅ តាមការសម្របសម្រួលដោយសហព័ន្ធស្រូវអង្ករកម្ពុជា

## ១២

### អត្ថប្រយោជន៍ពិសេសៗ

ទទួលបានការលើកទឹកចិត្តនានាពីរាជរដ្ឋាភិបាល លើកិច្ចការមួយចំនួនដូចជា ពន្ធដារ ថ្លៃអគ្គិសនី ការវាយតំលៃលើការប៉ះពាល់បរិស្ថាន (EIA) និងលក្ខខណ្ឌច្បាប់តម្រូវមួយចំនួន ក្រោមកិច្ចសម្របសម្រួលពីសហព័ន្ធស្រូវអង្ករកម្ពុជា ទៅកាន់ស្ថាប័នទាំងនោះ។

# ៣. នីតិវិធីស្នើសុំចូលជាសមាជិក

បំពេញ ៖

១. ពាក្យសុំចូលជាសមាជិក (ផ្តល់ដោយសហព័ន្ធស្រូវអង្ករកម្ពុជា)

២. កិច្ចព្រមព្រៀងអនុវត្តន៍លើសេចក្តីប្រកាសរួមស្តីអំពីក្រមសីលធម៌ (ផ្តល់ដោយសហព័ន្ធស្រូវអង្ករកម្ពុជា)

៣. កិច្ចព្រមព្រៀងអនុវត្តន៍លើកាតព្វកិច្ចជាសមាជិកដែលកំណត់ដោយបទបញ្ញាផ្ទៃក្នុងនិងលក្ខន្តិកៈ (ផ្តល់ដោយសហព័ន្ធស្រូវអង្ករកម្ពុជា)

ភ្ជាប់មកជាមួយ ៖

- វិញ្ញាបនបត្រការចុះបញ្ជីពាណិជ្ជកម្ម (ថតចម្លង១ច្បាប់)
- ប័ណ្ណប៉ាតង់/ពន្ធដារ (ថតចម្លង១ច្បាប់)
- ប័ណ្ណចុះបញ្ជី ឬលិខិតទទួលស្គាល់ចុះបញ្ជី (សម្រាប់សហគមន៍កសិកម្ម)

# ៤. ភាតព្វកិច្ចរបស់សមាជិក

គោរពនិងអនុវត្តក្រម
សីលធម៌ដែលបាន
ព្រមព្រៀង

ចូលរួមយ៉ាងសកម្ម និងគាំទ្រ
នូវបេសកកម្ម គោលដៅ
និងសកម្មភាពរបស់សហព័ន្ធ
ស្រូវអង្ករកម្ពុជា ដើម្បីសម្រេច
នូវទស្សនវិស័យរបស់សហព័ន្ធ
ស្រូវអង្ករកម្ពុជា

គោរពនូវកាតព្វកិច្ចរបស់
សមាជិកដូចមានចែងក្នុង
លក្ខន្តិកៈ និងបទបញ្ជាផ្ទៃ
ក្នុងរបស់សហព័ន្ធ
ស្រូវអង្ករកម្ពុជា

# ទំនាក់ទំនង

(855) 23 559 8999

(855) 93 300 496

(855) 16 242 033

info@crf.org.kh

www.crf.org.kh

https://www.facebook.com/cambodiaricefederation/

https://twitter.com/RiceCrf

សហព័ន្ធស្រូវអង្ករកម្ពុជា

Cambodia Rice Federation



ស.អ.ក

សហព័ន្ធស្រូវអង្ករកម្ពុជា

CAMBODIA RICE FEDERATION

# សូមអរគុណ

